# វត្តខេមររង្សីសាជីវកម្មអេស៊ីធី

KHEMARARANGSI BUDDHIST TEMPLE OF THE ACT INC. (ABN: 59 458 534 934)

1 Ross Smith Cres, Scullin ACT 2614 Australia Phone: +61 2 6255 2428

Facebook: www.facebook.com/khemararangsiACT/

Website: www.khemararangsi.org Email: khemararangsi@gmail.com




## បុណ្យកឋិនទានសាមគ្គី វត្តខេមររង្សី



## You are invited to the Kathinnatean Samaki Celebration on 31 October 2026

យើងខ្ញុំទាំងអស់គ្នា ជាពុទ្ធបរិស័ទនៅទីក្រុង **ខេនប៊ែរ៉ា** និង**ស៊ីដនីយ៍** ព្រមទាំងញាតិមិត្តជិតឆ្ងាយទាំងអស់បានស្រុះស្រួលមូលមតិគ្នាជាឯកច្ឆ័ន្ទផ្តើមធ្វើអង្គកឋិនទានសាមគ្គីដើម្បីដង្ហែយកទៅវេរប្រគេនព្រះ ភិក្ខុសង្ឃ ដែលគង់ចាំវស្សាអស់ត្រីមាសនៅ **វត្តខេមររង្សី**។

**អាស្រ័យហេតុនេះ** យើងខ្ញុំសូមគោរពនិមន្ត និងអញ្ជើញពុទ្ធបរិស័ទញាតិមិត្តជិតឆ្ងាយទាំងអស់មេត្តាចូលរួមក្នុងកម្មវិធីបុណ្យកឋិនទាននេះ ឱ្យបានច្រើនកុះករ ដើម្បីទទួលអនុមោទនាយកនូវមគ្គផល មហាកុសល និងផលានិសង្សតាមកម្លាំងសទ្ធាជ្រះ ថ្លារៀងៗខ្លួន។

### អ្នកផ្តើមបុណ្យ

- លោកគ្រូ **វិរិយប្បិយោ ជួន ហួត** ចៅអធិការ **វត្តខ្មែរស៊ីដនីយ៍**
- លោកគ្រូ **វិសាលថេរ យីប ហា** ចៅអធិការ **វត្តរ៉ូស្ម៉េរ**
- គណៈកម្មការ និងពុទ្ធបរិស័ទនៅ **វត្តខ្មែរស៊ីដនីយ៍** និង**វត្តកេតនៈ (រ៉ូស្ម៉េរ)**
- គណៈកម្មការ និងពុទ្ធបរិស័ទនៅទីក្រុង**ខេនប៊ែរ៉ា** ។

## កម្មវិធីបុណ្យ

**ថ្ងៃសុក្រ ៤រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០ ត្រូវនឹង**
**ថ្ងៃសុក្រ ទី ៣០ ខែតុលា ឆ្នាំ២០២៦**

- ចាប់ពីម៉ោង ៥:00 រសៀល ជួបជុំពុទ្ធបរិស័ទ
- ម៉ោង ៦:00 ល្ងាច នមស្ការ សមាទានសីលនិមន្តព្រះសង្ឃចម្រើន ព្រះបរិត្ត និងសម្តែងព្រះធម៌ទេសនា។

**ព្រឹកឡើងថ្ងៃសៅរ៍ ៥រោច ត្រូវនឹងថ្ងៃទី៣១ ខែឆ្នាំដដែល**

- ចាប់ពីម៉ោង ៩:00 ព្រឹក ជួបជុំពុទ្ធបរិស័ទ និងដង្ហែអង្គកឋិនទាន
- ម៉ោង ១០:00 ព្រឹក នមស្ការ សមាទានសីល
- ម៉ោង ១១:00 ព្រឹក វេរភត្តាហារប្រគេនព្រះសង្ឃ បន្ទាប់មក ពុទ្ធបរិស័ទពិសាភោជនាហារ។ ម៉ោង ១:00 ល្ងាច វេរអង្គកឋិនទាន ប្រគេនព្រះសង្ឃក្រាលគ្រងជាកិច្ចបញ្ចប់បុណ្យ។

**ពត៌មានបន្ថែម** សូមទាក់ទង តាមទូរស័ព្ទលេខ
០៤ ២៣២២ ១០៦១, ០៤ ៣៤១២ ៦២២៧, ០៤ ២២៣៣ ៦៦៩៤

### Kathinnatean Samaki Ceremony Invitation

Join us for the Kathinnatean Samaki at Khemararangsi Buddhist Temple on Saturday 31 October 2026.

This special event is to offer Kathinnatean robes to the Sangha after their retreat season and to reconnect, pray, hear Buddhist teachings and receive blessings.

### Hosted by

- Viriyabbiyo HUOT CHUON
- Visalthera HA YIB
- Committees and laypeople from Canberra and Sydney

### Schedule

**Friday 30 October 2026**

- 5:00pm Guest arrival
- 6:00pm Chanting, Dharma talk, Five Precepts

**Saturday 31 October 2026**

- 9:00am Guest arrival
- 10:00am Ceremony begins
- 11:00am Lunch offering to Sangha, then lunch for guests
- 1:00pm Robe offering and closing

**Contact:**
04 2322 1061 | 04 3412 6227 | 04 2233 6694